ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១១២៣.សរណ

# ជម្រាបមក

## ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

## និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត

**កម្មវត្ថុ** : ស្តីពីការចាត់វិធានការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។

**យោង** : បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០២ បប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាប **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត** ជ្រាបថា ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល ដូចមានចុះយោងខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវ** នូវវិធានការអនុវត្តចាំបាច់មួយចំនួនដូចខាងក្រោម៖

- ត្រូវដឹកនាំកងកម្លាំងនគរបាល កងរាជអាវុធហត្ថ និងអាជ្ញាធរមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការសហការរៀបចំគោលដៅត្រួតពិនិត្យ និងការហាមឃាត់ការធ្វើដំណើរស្របតាមបទបញ្ជារបស់រាជរដ្ឋាភិបាល។
- ត្រូវសម្របសម្រួលក្នុងការធ្វើដំណើរឆ្លងកាត់ចេញ ចូល រវាងរាជធានី និងខេត្ត ដូចមានចែងក្នុងចំណុចទី២ នៃបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។
- ត្រូវយកចិត្តទុកដាក់ការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ចំពោះគោលដៅនយោបាយការទូត និងការវិនិយោគ ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ក្នុងការអនុវត្តបទបញ្ជាខាងលើនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវខិតខំសម្របសម្រួល ដោះស្រាយ និងបញ្ចៀសឱ្យបាននូវអំពើហិង្សាគ្រប់រូបភាព។ ទន្ទឹមនេះ ត្រូវខិតខំធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំដល់ប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យយល់ជ្រួតជ្រាបអំពីគោលបំណងរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមគោរព និងសហការអនុវត្តតាមស្មារតីបទបញ្ជារបស់រាជរដ្ឋាភិបាល សំដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩នៅកម្ពុជា ក៏ដូចជាថែរក្សាសុខភាពសាធារណៈ និងការពារនូវអាយុជីវិតរបស់ប្រជាពលរដ្ឋ។

- ត្រូវរៀបចំក្រុមប្រចាំការដើម្បីប្រមូលព័ត៌មានដែលបានកើតឡើងក្នុងរាជធានី ខេត្តរបស់ខ្លួន ពាក់ព័ន្ធនឹងការអនុវត្តបទបញ្ជានេះ ហើយត្រូវខិតខំសម្របសម្រួលដោះស្រាយបាតុភាពនានាឱ្យបានល្អប្រសើរ។ ក្នុងករណីដែលមិនអាចដោះស្រាយបាន ត្រូវរាយការណ៍ជូនក្រុមប្រចាំការដើម្បីធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ក្នុងការអនុវត្តបទបញ្ជាលេខ ០២ បប ស្ដីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវដឹកនាំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីប្រមូលកងកម្លាំងសរុប មធ្យោបាយសរុបក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល និងគ្រប់គ្រងសភាពការណ៍នៅតាមមូលដ្ឋានរបស់ខ្លួនឱ្យបានល្អប្រសើរ។
- ចំពោះខេត្តជាប់ព្រំដែនកម្ពុជា ថៃ (ខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ) ត្រូវបន្តសម្របសម្រួលជាមួយភាគីថៃ ក្នុងករណីដែលមានប្រជាពលរដ្ឋវិលត្រលប់ចូលមកកម្ពុជាតាមច្រកព្រំដែនកំណត់ណាមួយដែលបានឯកភាពគ្នា ដើម្បីងាយស្រួលក្នុងការសម្របសម្រួល និងគ្រប់គ្រង។ ទន្ទឹមនេះ រដ្ឋបាលខេត្តទាំង០៣ ខាងលើ ត្រូវសម្របសម្រួលជាមួយរដ្ឋបាលរាជធានី ខេត្តនានា ក្នុងរៀបចំគណៈបញ្ជាការស្រាលនៃខេត្តរបស់ខ្លួន ដើម្បីសម្របសម្រួលដឹកជញ្ជូនពលករ ដែលវិលត្រលប់ពីប្រទេសថៃទៅកាន់មណ្ឌលត្រួតពិនិត្យសុខភាពនៃខេត្តជាប់ព្រំដែនកម្ពុជា ថៃទាំង០៣ តាមមធ្យោបាយដឹកជញ្ជូនដែលរាជរដ្ឋាភិបាលបានរៀបចំ ដើម្បីអនុវត្តវិធានការចត្តាឡីស័ក ដែលកំណត់ដោយក្រសួងសុខាភិបាល។ បន្ទាប់ពីនេះ រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំមធ្យោបាយដឹកជញ្ជូនប្រជាពលរដ្ឋទាំងនោះ ទៅកាន់មណ្ឌលត្រួតពិនិត្យសុខភាពរាជធានី ខេត្តរបស់ខ្លួន មុននឹងបញ្ជូនបងប្អូនប្រជាពលរដ្ឋទៅកាន់លំនៅឋានរៀងៗខ្លួន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត** ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានពីខ្ញុំ។

ថ្ងៃ សុក្រ ៣រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកសារ-កាលប្បវត្តិ